ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តិបាលកម្ពុជា
...៥៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការដាក់មន្ត្រីរាជការអោយនៅក្រៅក្របខ័ណ្ឌដើម ក្នុងពេលទៅបំពេញការងាររៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

---

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ .នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤.៨៣ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦នស៩៤ ចុះថ្ងៃទី៣០ខែតុលាឆ្នាំ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត ០៨៩៧.១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស.រកម ១១៩៧.០៥ ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស រកម ១២៩៧.០៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ
- តាមសំណើររបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ១៩៩៨

## សំរេច

ប្រការ ១: មន្ត្រីរាជការដែលត្រូវបានតែងតាំងជាប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការ

បោះឆ្នោតត្រូវដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់មានការតែងតាំងថ្មី។ ក្នុងរយៈពេលនេះ សាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសំរាប់ការឡើងថ្នាក់និងទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ ។

**មាត្រា ២:** មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកនៃគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត មន្ត្រីបំរើអោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង មន្ត្រីបំរើអោយគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់ចប់ភារកិច្ច ។ ក្នុងរយៈពេលនេះសាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសំរាប់ការឡើងថ្នាក់និងទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ ។

**មាត្រា ៣:** មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំឈប់ពិសេសទៅបំរើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់ថ្ងៃប្រកាសលទ្ធផលបោះឆ្នោតជាស្ថាពរ ។

- មន្ត្រីរាជការបំរើអោយគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវដាក់ពាក្យសុំឈប់ពិសេសទៅបំរើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់ថ្ងៃចប់ភារកិច្ច ។

ក្នុងការឈប់ពិសេសនេះមន្ត្រីរាជការត្រូវបានរក្សាបៀវត្សអតីតភាពការងារសំរាប់ការឡើងថ្នាក់ និង ទទួលសោធននិវត្តន៍ ។

**មាត្រា ៤:** មន្ត្រីរាជការដែលត្រូវបានតែងតាំងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មានសិទ្ធិទទួលការអនុញ្ញាតអោយឈប់ពីការងារដើម្បីបំរើការរៀបចំការបោះឆ្នោត និងចូលបំរើការងារនៅអង្គភាពដើមវិញក្រោយពីចប់ភារកិច្ច ។

លិខិតអនុញ្ញាតអោយឈប់សំរាករបស់ក្រសួង ស្ថាប័ន ឬអង្គភាព ត្រូវចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៥:** មន្ត្រីរាជការមួយឬពីររូបដែលត្រូវនៅបន្តនិរន្តរ៍ភាពការងារបោះឆ្នោតនៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវសុំបន្តការងារនៅក្រៅក្របខ័ណ្ឌដើមចាប់ពី ៦០ ថ្ងៃក្រោយការប្រកាសលទ្ធផលជាស្ថាពររហូតដល់ពេលរៀបចំការបោះឆ្នោតអាណត្តិក្រោយ ។ ក្នុងរយៈពេលនេះ សាមីខ្លួនមានសិទ្ធិរក្សាអតីតភាពការងារសំរាប់ឡើងថ្នាក់ និងទទួលសោធន៍និវត្តន៍ ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និង មន្ត្រីរាជការដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយបានល្អចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ១៩៩៨

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

**អ៊ឹង ហួត** **ហ៊ុន សែន**

*កន្លែងទទួល :*

- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការរដ្ឋសភា*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី ១*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី ២*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *គ្រប់ក្រសួង ស្ថាប័ន*
- *ឯកសារ - កាលប្បវត្តិ*

បានយកសេចក្តីជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១ និងសម្តេចនាយករដ្ឋមន្ត្រីទី ២

ដើម្បីសូមចុះហត្ថលេខា

**សហរដ្ឋមន្ត្រី**

ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ស្តីទី

**សុខ អាន** **ឈាវី តាន់**